# សលាកបត្រព័ត៌មាន៖ ការបណ្តេញចេញដោយបង្ខំនៅប្រទេសកម្ពុជា

**ទិដ្ឋភាពរួម៖** សលាកបត្រព័ត៌មាននេះត្រូវបានចងក្រងឡើង ដើម្បីបំពេញបន្ថែមទៅលើសលាកបត្រព័ត៌មានមុនៗ ដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានចេញផ្សាយក្នុងឆ្នាំ២០២០,២០២១ និង២០២៣។ សលាកបត្រព័ត៌មាននេះបានផ្តោតលើការបណ្តេញចេញដោយបង្ខំនៅកម្ពុជាតាំងពីខែតុលា ឆ្នាំ២០២៣ រំលឹកឡើងវិញអំពីកាតព្វកិច្ចសិទ្ធិមនុស្សដែលរដ្ឋ និងធុរកិច្ចនានា ត្រូវការពារពលរដ្ឋពីការបណ្តេញចេញដោយបង្ខំ និងផ្តល់ជាអនុសាសន៍ជាក់លាក់ដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីការការពារសិទ្ធិលំនៅដ្ឋាន និងសិទ្ធិដីធ្លី ។

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាមានប្រវត្តិពាក់ព័ន្ធនឹងការការបណ្តេញចេញដោយបង្ខំជាយូរមកហើយ ហើយជម្លោះដីធ្លីមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ដោយសារការផ្តល់ដីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ចន្លោះប្រហោងនៃប្រព័ន្ធចុះបញ្ជីដីធ្លី កង្វះសន្តិសុខនៃសិទ្ធិកាន់កាប់ដីធ្លីជាផ្លូវការ និងនីតិរដ្ឋទន់ខ្សោយ។ ទោះបីជាពុំមានទិន្នន័យជាផ្លូវការក្តី យ៉ាងហោចមានប្រជាពលរដ្ឋកម្ពុជាប្រមាណ **៤០០.០០០ នាក់** ត្រូវបានបណ្តេញចេញដោយបង្ខំនៅចន្លោះឆ្នាំ២០០៣ ដល់ឆ្នាំ២០១២[1] ប៉ុន្តែបច្ចុប្បន្ន ចំនួននេះត្រូវបានរំពឹងថាកើនឡើងជាងនេះ។ របាយការណ៍ឆ្នាំ២០២០ របស់សមាគមធាងត្នោត បានបង្ហាញថា នៅក្នុងរាជធានីភ្នំពេញតែមួយប៉ុណ្ណោះ មានប្រជាពលរដ្ឋ**ជិត ១០.០០០ គ្រួសារ (ប្រមាណ ៤០.០០០ នាក់)** ត្រូវបានបណ្តេញចេញដោយពុំបានអនុវត្តតាមនីតិវិធីត្រឹមត្រូវ តាំងពីអំឡុងទសវត្សរ៍ឆ្នាំទសវត្សរ៍ឆ្នាំ១៩៨០ មកម្ល៉េះ។[2]

ការបណ្តេញចេញដោយបង្ខំ ជារឿយៗបានរុញច្រានជនរងគ្រោះឱ្យធ្លាក់ចូលទៅក្នុងភាពគ្មានផ្ទះសម្បែង ឬរារាំងពួកគាត់ពីការប្រកបមុខរបរចិញ្ចឹមជីវិត។ ការបណ្តេញចេញដោយបង្ខំ**បង្កើនវិសមភាពដែលមានស្រាប់** ហើយនោះរឹតតែ**ប៉ះពាល់ដល់សហគមន៍ក្រីក្រ និងសហគមន៍ដែលត្រូវបានគេផាត់ចោល** ធ្វើឱ្យប្រជាពលរដ្ឋដែលងាយរងគ្រោះទាំងនោះកាន់តែធ្លាក់ចូលទៅក្នុងភាពក្រីក្របន្ថែមទៀត។ សលាកបត្រព័ត៌មានមុនៗ ដែលចេញផ្សាយដោយ ម.ស.ម.ក ក្នុងឆ្នាំ២០២០ និង២០២១ បង្ហាញថា ការបណ្តេញចេញដោយបង្ខំនៅតែ**បន្តកើតមានក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩**[3] បើទោះជាអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមានលំនៅ

[1] ហ្វេនគ្រីនវូដ «ការបណ្តេញចេញនៅកម្ពុជាបន្តដោយពុំមានការត្រួតពិនិត្យ» (ភ្នូមពេញប៉ុស្តិ៍ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១២)

[2] សមាគមធាងត្នោត «ការបណ្តេញចេញ និងការតាំងលំនៅជាថ្មី» (ខែមិថុនា ឆ្នាំ២០២០)

[3] ម.ស.ម.ក «សលាកប័ត្រព័ត៌មាន៖ ការបណ្តេញចេញដោយបង្ខំនៅកម្ពុជា» (ខែតុលា ឆ្នាំ២០២០); ម.ស.ម.ក «សលាកប័ត្រព័ត៌មានស្តីពី

ឋានសមរម្យ បានអំពាវនាវឱ្យផ្អាកជាសកលចំពោះការបណ្តេញចេញក្នុងអំឡុងពេលនោះក៏ដោយ។[4] នៅខែតុលា ឆ្នាំ ២០២៣ សលាកបត្រព័ត៌មានមួយទៀតបានចងក្រងឡើងទុកជាឯកសារអំពីករណីជាច្រើនទៀតនៃការបណ្តេញចេញដោយបង្ខំ ចាប់តាំងពីការលុបបម្រាមកូវីដ-១៩ នៅចុងឆ្នាំ ២០២១។[5]

សលាកបត្រព័ត៌មាននេះ នឹងបង្ហាញអំពីកាតព្វកិច្ចសិទ្ធិមនុស្សដែលទាមទារឱ្យរដ្ឋ និងធុរកិច្ចត្រូវការពារបុគ្គលគ្រប់រូបនិងសហគមន៍ពីការបណ្តេញចេញដោយបង្ខំ។ សលាកបត្រព័ត៌មាននេះក៏ពិនិត្យមើលករណីថ្មីៗនៃការបណ្តេញចេញដោយបង្ខំនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីខែតុលា ឆ្នាំ២០២៣ និងផ្តល់អនុសាសន៍ជាក់លាក់ដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រឹងការគោរពសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន និងទប់ស្កាត់ការបណ្តេញចេញដោយបង្ខំនៅក្នុងប្រទេសកម្ពុជា។

## ក. និយមន័យ

**តើអ្វីទៅជាការបណ្តេញចេញដោយបង្ខំ?**

ការបណ្តេញចេញដោយបង្ខំគឺជា «**ការជម្លៀសបុគ្គល គ្រួសារ និង/ឬសហគមន៍ជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ ចេញពីផ្ទះ និង/ឬដីធ្លីរបស់ពួកគេដែលកំពុងកាន់កាប់ ដែលផ្ទុយពីឆន្ទៈរបស់ពួកគាត់** ដោយគ្មានការផ្តល់ និងការទទួលបាននូវទម្រង់សមស្របនៃការការពារស្របច្បាប់ឬទម្រង់ការពារផ្សេងទៀត»។

គណៈកម្មាធិការ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (មតិទូទៅលេខ៧ អ៊ី/១៩៩៨/២២ ១៩៩៧)

ការបណ្តេញចេញដោយបង្ខំ គឺជា**ការរំលោភបំពានដ៏ធ្ងន់ធ្ងរ**ទៅលើសិទ្ធិមានលំនៅឋានសមរម្យ ក៏ដូចជាសិទ្ធិទាំងឡាយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ រួមទាំងសិទ្ធិសន្តិសុខរបស់បុគ្គល និងសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការកាន់កាប់ដី និងដែនដីប្រពៃណីរបស់ខ្លួន។[6] នៅក្រោមច្បាប់អន្តរជាតិ ការបណ្តេញចេញដោយបង្ខំគឺអាចអនុញ្ញាតបានតែក្នុងកាលៈទេសៈដែលគ្មានជម្រើស និងតិចតួចបំផុត ហើយត្រូវ**មានហេតុផលពេញលេញ និងអនុញ្ញាតដោយច្បាប់។ ការផ្តល់សំណង និងដំណោះស្រាយតាមផ្លូវច្បាប់**ពេញលេញត្រូវតែមានសម្រាប់អ្នកដែលរងផលប៉ះពាល់។[7]

---

ការបណ្តេញចេញដោយបង្ខំនៅកម្ពុជាអំឡុងពេលកូវីដ-១៩ ឆ្នាំ២០២១» (ខែតុលា ឆ្នាំ២០២១)

[4] ម.ស.ម.ក «អ្នកជំនាញអង្គការសហប្រជាជាតិជំរុញឱ្យហាមឃាត់ការបណ្តេញចេញអំឡុងពេលផ្ទុះជំងឺរាតត្បាតកូវីដ-១៩» (ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០)

[5] ម.ស.ម.ក «សលាកប័ត្រព័ត៌មានះ ការបណ្តេញចេញដោយបង្ខំនៅកម្ពុជា» (ខែតុលា ឆ្នាំ២០២៣)

[6] «សលាកបត្រព័ត៌មានស្តីពីការបណ្តេញចេញដោយបង្ខំ លេខ ២៥/Rev ១» (អូ.អេធ.ស៊ី.អេធ.អ ២០១៥) ទំព័រទី ៥

[7] អូ.អេធ.ស៊ី.អេធ.អ «មតិទូទៅលេខ ៧ ស្តីពីសិទ្ធិមានលំនៅឋានគ្រប់គ្រាន់៖ ការបណ្តេញចេញដោយបង្ខំ» (ក.អ.ស.ស.ស.វ ១៩៩៧) ឯកសារ អ.ស.ប ឯកសារ អ៊ី/១៩៩៨/២២ កថាខណ្ឌទី ១១។

**រដ្ឋមានទំនួលខុសត្រូវក្នុងការការពារពីការបណ្តេញចេញដោយបង្ខំ** និងធានាថាការបណ្តេញចេញត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីសិទ្ធិមនុស្សនិងអនុវត្តក្នុងលក្ខខណ្ឌសមស្រប។ ក្នុងនោះ រាប់បញ្ចូលទាំងការពិចារណាអំពីជម្រើសជំនួសការបណ្តេញចេញ ការអនុវត្តតាមនីតិវិធីត្រឹមត្រូវ និង**ការគោរពសិទ្ធិទទួលបានព័ត៌មាន ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត** ពីសំណាក់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់។

រដ្ឋក៏ត្រូវចាត់វិធានការចាំបាច់ទាំងអស់ដើម្បី**កាត់បន្ថយផលប៉ះពាល់ជាអប្បបរិមា នៃការបណ្តេញចេញ** កុំឱ្យការបណ្តេញចេញទាំងនោះឈានដល់ភាពគ្មានផ្ទះសម្បែង[8] និងធានាថាប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញបានទទួល**សំណងគ្រប់គ្រាន់**ជាមុន និងដំណោះស្រាយសមស្របបំផុត។[9]

រដ្ឋទាំងឡាយក៏ត្រូវបានតម្រូវឱ្យការពារទល់នឹងការបណ្តេញចេញដោយបង្ខំ ដែលប្រព្រឹត្តឡើងដោយភាគីទីបីផងដែរ ក្នុងខណៈដែល**ធុរកិច្ចក៏មានកាតព្វកិច្ចក្នុងការគោរពសិទ្ធិមនុស្ស** រួមទាំងការមិនបណ្តេញបុគ្គលចេញដោយបង្ខំផងដែរ។[10] ជាការសំខាន់ណាស់ ដែលត្រូវរំលឹកថាការការពារទល់នឹងការបណ្តេញចេញដោយបង្ខំ**មិនអាស្រ័យតែលើស្ថានភាពកម្មសិទ្ធិកាន់កាប់ដីធ្លីរបស់បុគ្គលនោះឡើយ** ប៉ុន្តែការការពារនោះត្រូវគ្របដណ្តប់ទៅលើ***បុគ្គលគ្រប់រូប***រួមទាំងអ្នកដែលតាំងទីលំនៅមិនទាន់ផ្លូវការ នៅទីជនបទ និងអ្នកជួលផងដែរ។[11]

## ខ. ក្របខណ្ឌច្បាប់

ការការពារពីការបណ្តេញចេញដោយបង្ខំ មានចែងនៅក្នុងសន្ធិសញ្ញាជាកាតព្វកិច្ចតាមផ្លូវច្បាប់ដែលកម្ពុជាបានផ្តល់សច្ចាប័ន[12] ហើយត្រូវបានបញ្ចូលទៅក្នុងច្បាប់ជាតិតាមរយៈមាត្រា៣១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជាក់ស្តែងមាត្រា១១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ («ក.អ.ស.ស.ស.វ») ទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការរស់នៅសមរម្យគ្រប់គ្រាន់ រួមទាំងសិទ្ធិមាន**លំនៅឋានសមរម្យ** ផងដែរ ដែលក្នុងនោះ មាត្រា១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ («ក.អ.ស.ព.ន») បានចែងថាគ្មានជនណាម្នាក់ត្រូវទទួលរង**ការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងលំនៅឋានរបស់ខ្លួនឡើយ**។

---

[8] ប្រភពដូចបានដាក់បង្ហាញនៅលេខយោង៧ ខាងលើ (ក្របខណ្ឌទី ១៦)

[9] សម្រាប់ឧទាហរណ៍អំពីដំណោះស្រាយសមស្រប សូមមើល អូ.អេច.ស៊ី.អេច.អ «ស្តង់ដារ និងការអនុវត្តសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន» (អូ.អេច.ស៊ី.អេច.អ ២០១៥) ទំព័រទី ២៩ ។

[10] អូ.អេច.ស៊ី.អេច.អ «ស្តង់ដារ និងការអនុវត្តសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន» (អិន ៦) ទំព័រទី ៨១

[11] ប្រពភដូចបានដាក់បង្ហាញនៅលេខយោង ១០ ខាងលើ ទំព័រទី ៧

[12] សម្រាប់ព័ត៌មានស្តីពីសិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់រដ្ឋក្រោមច្បាប់អន្តរជាតិទាក់ទងនឹងការបណ្តេញចេញដោយបង្ខំ សូមចូលទៅអានឯកសាររបស់អ្នករាយការណ៍ពិសេសស្តីពីលំនៅឋានគ្រប់គ្រាន់៖ «គោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការផ្លាស់ទីលំនៅសម្រាប់ការអភិវឌ្ឍន៍»។ (អូ.អេច.ស៊ី.អេច.អ ២០០៧) ឯកសារ អ.ស.ប ឯកសារ អេ/អេច អ ស៊ី/៤/១៨

ច្បាប់កម្ពុជាក៏បានចែងអំពីការពារជាច្រើនទល់នឹងការបណ្តេញចេញដោយបង្ខំ។ រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជានិងច្បាប់ភូមិបាលឆ្នាំ២០០១ បានចែងថា ការដកហូតដីធ្លី/អចលនវត្ថុអាចកើតឡើងទៅបានក្រោមហេតុផលដែលជាប្រយោជន៍សាធារណៈប៉ុណ្ណោះ ដោយមានការតម្រូវឱ្យផ្តល់**សំណងត្រឹមត្រូវនិងយុត្តិធម៌**ជាមុន។[13] ច្បាប់ភូមិបាលចែងបន្ថែមទៀតអំពីសិទ្ធិភោគៈ និងសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធដីធ្លីក្នុងកាលៈទេសៈជាក់លាក់[14] ហើយមានបញ្ញត្តិការពារពីការបណ្តេញចេញដោយបង្ខំចំពោះកម្មសិទ្ធិករ និងអ្នកកាន់កាប់ឯកជន។[15] ច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០ ក៏ចែងអំពីលក្ខខណ្ឌទាមទារឱ្យមានសំណងសមរម្យផងដែរ។

នៅឆ្នាំ២០០២ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្ត *«ការបញ្ជាក់ និងកត់ត្រាភាពជាម្ចាស់ និងសិទ្ធិផ្សេងៗទៀត [...] ដើម្បី**ពង្រឹងសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លី** លើកកម្ពស់ប្រសិទ្ធភាព និងភាពជឿជាក់បាននៃទីផ្សារដីធ្លី និងការពារភាពសុខដុមក្នុងសង្គមតាមរយៈការទប់ស្កាត់និងការដោះស្រាយជម្លោះដីធ្លី»* ។[16] រាជរដ្ឋាភិបាលកម្ពុជាក៏បានបង្កើតក្របខណ្ឌច្បាប់ គោលនយោបាយ និងស្ថាប័ន ដើម្បីអនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១។ ក្របខណ្ឌទាំងនេះទទួលស្គាល់ និងផ្តល់**ការការពារសំខាន់ៗ** ដើម្បីការពារសុវត្ថិភាពកាន់កាប់ដីធ្លី ក៏ដូចជាសិទ្ធិភោគៈ និងកម្មសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា រួមទាំងការការពារទល់នឹងការបណ្តេញចេញដោយបង្ខំផងដែរ។ ក្រោមគោលនយោបាយទាំងនេះ **ការបណ្តេញចេញដោយបង្ខំគឺជាអំពើខុសច្បាប់** ហើយការតាំងទីលំនៅថ្មីអាចធ្វើទៅបាន តែចំពោះវិធានការនិងជម្រើសចុងក្រោយប៉ុណ្ណោះ។[17]

## ២. ករណីថ្មីៗនៃការបណ្តេញចេញដោយបង្ខំនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ**កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិទ្រង់ទ្រាយធំមួយ ដើម្បីផ្តល់សុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីជាផ្លូវការ**នៅទូទាំងប្រទេសកម្ពុជា ដែលជាចំណាត់ការមួយក្នុងក្តីរំពឹងថា នឹងមានការកាត់បន្ថយការបណ្តេញចេញដោយបង្ខំ។ រាជរដ្ឋាភិបាលអាណត្តិមុនបានវាស់វែង និងចុះបញ្ជីក្បាលដីជាង ៧,៧ លាន ក្បាលដី **ដោយបានចេញប័ណ្ណកម្មសិទ្ធិប្រមាណ ៧ លាន ប័ណ្ណ**។ ការងារនេះបានបន្តរហូតមកដល់អាណត្តិក្រោមការដឹកនាំ

---

[13] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ៤៤ ។ ទន្ទឹមនឹងនេះ សូមមើល ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា ៥

[14] ឧទាហរណ៍ មាត្រា ៣០ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ចែងអំពីសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីជាក់លាក់ សម្រាប់អ្នកដែលបានកាន់កាប់ដីធ្លី និងលំនៅឋានដោយសន្តិវិធី និងគ្មានជម្លោះ លើសពីប្រាំឆ្នាំឡើងទៅ មុនពេលច្បាប់នេះត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់។

[15] សូមមើលច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ២៥៤។

[16] «ការបណ្តេញចេញ និងការតាំងលំនៅជាថ្មីនៅកម្ពុជា ការខាតបង់មនុស្ស ផលប៉ះពាល់ និងដំណោះស្រាយ» អូ.អេច.ស៊ី.អេច.អ ២០១២) ទំព័រទី ២។

[17] គោលការណ៍នេះត្រូវបាននិយាយបញ្ជាក់ជាថ្មី ដោយឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅពេលឯកឧត្តមទទួលជួបជាមួយឧត្តមស្នងការរងអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស លោកស្រី គ្យុង វ៉ាកាង នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១០ ។ អូ.អេច.ស៊ី.អេច.អ «ការបណ្តេញចេញ និងការតាំងលំនៅជាថ្មីនៅកម្ពុជា ការខាតបង់មនុស្ស ផលប៉ះពាល់ និងដំណោះស្រាយ» ឆ្នាំ២០១២ ទំព័រទី ២ ។

របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ដោយបានចុះបញ្ជីក្បាលដីចំនួន ២ លានក្បាលដី និងចេញប្លង់កម្មសិទ្ធិជិត ៥៩០.០០០ ប័ណ្ណ គិតត្រឹមថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤។ លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានសន្យាផ្តល់ថវិកាប្រមាណ ១០០ លានដុល្លារសហរដ្ឋអាមេរិក ដើម្បីវាស់វែងដីធ្លីឱ្យបានចំនួន ២,៥ លានក្បាលដី បន្ថែមទៀត និង**បិទបញ្ចប់ទាំងស្រុងនូវការងារចេញប័ណ្ណកម្មសិទ្ធិនៅឆ្នាំ២០២៥** ដោយមានគោលបំណងកាត់បន្ថយឱ្យបានច្រើនបំផុត ឬលុបបំបាត់ទាំងស្រុងនូវវិវាទដីធ្លី ។[18]

ទោះបីជនជាតិដើមភាគតិច តាំងពីដើមមក បានរងផលប៉ះពាល់ពីការបណ្តេញចេញដោយសារតែការផ្តល់សម្បទានដីសេដ្ឋកិច្ច និងការទន្ទ្រានយកដីព្រៃឈើរបស់ពួកគាត់ពីសំណាក់តួអង្គសេដ្ឋកិច្ចក៏ដោយ ប៉ុន្តែ **ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់ពួកគាត់មានវឌ្ឍនភាពតិចតួចប៉ុណ្ណោះ**។ គិតត្រឹមខែកក្កដា ឆ្នាំ២០២៤ ក្នុងចំណោមសហគមន៍ជនជាតិដើមចំនួន ៤៥៨ សហគមន៍ របស់ប្រទេសកម្ពុជា មានតែ ៤៣ សហគមន៍ប៉ុណ្ណោះ បានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាព។[19]

ចាប់តាំងពីខែតុលា ឆ្នាំ២០២៣ មក ទោះបីជាការចេញប័ណ្ណកម្មសិទ្ធិដីធ្លីមានវឌ្ឍនភាពខ្លះក៏ដោយ ប៉ុន្តែការបណ្តេញចេញមិនបានបង្ហាញសញ្ញាថមថយផងដែរ។ ចាប់ពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ ដល់ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៤ («រយៈពេលរាយការណ៍») គម្រោងការការពារសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី និងធនធានធម្មជាតិ របស់ ម.ស.ម.ក បានកត់ត្រា**អត្ថបទសារព័ត៌មានសរុបចំនួន ៣៦៨ អត្ថបទ និងទាក់ទងនឹងការបណ្តេញចេញដោយបង្ខំ ចំនួន ៤០ ករណី** ក្នុងនោះមាន៨ ករណីត្រូវបានបណ្តេញចេញរួចហើយ និង ចំនួន៣២ ករណីទៀតកំពុងរងការគំរាមកំហែងនឹងការបណ្តេញចេញ។ ករណីទាំង៤០ នេះបានប៉ះពាល់ដល់**ប្រជាពលរដ្ឋប្រមាណ ២២.១០៨ គ្រួសារ ដែលត្រូវបានបណ្តេញចេញ ឬប្រឈមនឹងការបណ្តេញចេញ**នៅទូទាំងប្រទេស។ តួលេខដែលបានបង្ហាញនៅក្នុងកថាខណ្ឌនេះរួមមានទាំងករណីថ្មី និងករណីដែលបានចាប់ផ្តើមមុនពេលសលាកបត្រព័ត៌មាននេះត្រូវបានចងក្រងឡើង និងបន្តកើតមានជាបន្តបន្ទាប់ក្នុងអំឡុងពេលនៃការរាយការណ៍នេះ។ ដូច្នេះ តួលេខទាំងនេះមិនតំណាងឱ្យចំនួនពិតប្រាកដនៃប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញ ឬប្រឈមនឹងការបណ្តេញចេញ តែក្នុងអំឡុងពេលនៃការរាយការណ៍នេះឡើយ។

ការបណ្តេញចេញដោយបង្ខំនាពេលថ្មីៗនេះ ដែល ម.ស.ម.ក បានកត់ត្រាទុកទាំងនោះ រួមមានទាំង **ការប្រើប្រាស់កម្លាំង ការគំរាមកំហែងផ្លូវច្បាប់ ការបំភិតបំភ័យ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ កញ្ចប់សំណងមិនសមរម្យ និងកង្វះការពិគ្រោះយោបល់**ទូទៅជាមួយសហគមន៍ដែលរងផលប៉ះពាល់។ ជនរងគ្រោះចម្បងគឺជាសមាជិកសហគមន៍ក្រីក្រ កសិករ និងក្រុមងាយរងគ្រោះផ្សេងទៀត។ មាន **អ្នកការពារសិទ្ធិមនុស្សដ៏លេចធ្លោម្នាក់ត្រូវបាន**

[18] នៀម ឆេង «សង្គមស៊ីវិលសាទរចំពោះផែនការចំណាយ ១០០ លានដុល្លារ បញ្ចប់ការវាស់វែងដីធ្លីនៅឆ្នាំ២០២៥» (*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤)

[19] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា តាមរយៈទំព័រ ហ្វេសប៊ុក ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤

**ឃុំខ្លួន** ដោយសារតែបានចែករំលែក និងផ្សព្វផ្សាយអំពីបញ្ហាប្រឈមរបស់ជនរងគ្រោះដោយការបណ្តេញចេញដោយបង្ខំ។ ខាងក្រោមនេះគឺជាករណីលេចធ្លោចំនួនបីក្នុងចំណោមករណីធំៗ ដែលបានចងក្រងទុកក្នុងអំឡុងពេលរាយការណ៍។

## ក.ការផ្លាស់ប្តូរទីលំនៅក្នុងតំបន់អង្គរបង្កក្តីបារម្ភពីសក្តានុពលនៃការបណ្តេញចេញទ្រង់ទ្រាយធំ

នៅឆមាសទីពីរនៃឆ្នាំ២០២២ អាជ្ញាធរបានចាប់ផ្តើមការ**ផ្លាស់ប្តូរទីលំនៅរបស់ប្រជាពលរដ្ឋ ប្រមាណជាង ១០.០០០គ្រួសារ** ពីឧទ្យានបុរាណវិទ្យាអង្គរនៃខេត្តសៀមរាប ទៅកាន់ឃុំរុនតាឯក ស្រុកបន្ទាយស្រី ដែលមានចម្ងាយប្រហែល៣០ គីឡូម៉ែត្រ។ អាជ្ញាធរបាននិយាយថា ការផ្លាស់ប្តូរទីលំនៅគឺជារឿងចាំបាច់ដើម្បីការពារទីតាំងបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ ដោយបានពន្យល់ថាប្រជាពលរដ្ឋមានការស្ម័គ្រចិត្ត។[20] ទោះជាយ៉ាងណា ការស្រាវជ្រាវចេញផ្សាយដោយអង្គការលើកលែងទោសអន្តរជាតិក្នុងខែមីនា ឆ្នាំ២០២៣ បានបង្ហាញពីភាពខ្វះចន្លោះ *«ការជូនដំណឹងជាមុនអំពីការបណ្តេញចេញ និងការពិគ្រោះយោបល់ឱ្យបានច្បាស់លាស់ជាមួយសហគមន៍ដែលរងផលប៉ះពាល់ អំពីដំណើរការបណ្តេញចេញ និងការតាំងទីលំនៅថ្មី»*។[21] គិតត្រឹមខែមេសា ឆ្នាំ២០២៤ **ប្រជាពលរដ្ឋប្រមាណ ៥.០០០ គ្រួសារត្រូវបានផ្លាស់ប្តូរទីលំនៅរួចហើយ** និង ៥.០០០គ្រួសារ ផ្សេងទៀតនឹងនៅតែប្រឈមនឹងផ្លាស់ទីលំនៅចេញពីទីនោះ។[22]

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ របាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិបានរកឃើញថាប្រជាពលរដ្ឋជាច្រើនគ្រួសារ**ត្រូវបានរងសម្ពាធបង្ខំឱ្យចាកចេញ ដោយមានការបំភិតបំភ័យ ការឃាំឃើ ការគំរាមកំហែង និងអំពើហិង្សា**។ អង្គការលើកលែងទោសអន្តរជាតិបានគូសបញ្ជាក់ផងដែរថា តំបន់រុនតាឯកងាយនឹងមានទឹកជំនន់ និងខ្វះហេដ្ឋារចនាសម្ព័ន្ធចាំបាច់។ ក្រុមគ្រួសារប្រជាពលរដ្ឋដែលបានផ្លាស់ទីលំនៅក៏បានរាយការណ៍ថាប្រឈមនឹងការខ្វះស្បៀងអាហារ បន្ទាប់ពីបាត់បង់ប្រភពចំណូលសំខាន់របស់ពួកគាត់ ដែលធ្លាប់រកបាននៅតំបន់អង្គរ។[23] ជាការឆ្លើយតប អង្គការយូណេស្កូ**បានជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជាដាក់ចេញវិធានការកែតម្រូវ** និងណែនាំ

---

[20] យួន ណារីម និង ចិកប៊ុក «គ្មានជម្រើស៖ ការបណ្តេញចេញដោយបង្ខំពីតំបន់អង្គរ ត្រូវបានរៀបរាប់ប្រាប់ទៅយូណេស្កូថា ជាការស្ម័គ្រចិត្ត» (*ខេមបូចា* ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣)

[21] អង្គការលើកលែងទោសអន្តរជាតិ "កម្ពុជា៖ 'បញ្ឈប់ការបណ្តេញចេញទ្រង់ទ្រាយធំដោយបង្ខំ' នៅតំបន់បេតិកភ័ណ្ឌពិភពលោកអង្គរវត្ត" (ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២៣)

[22] ដាវីដ រ៉ាយស៊ីង «ការផ្លាស់ប្តូរទីលំនៅនៃប្រជាពលរដ្ឋកម្ពុជាចេញពីតំបន់បេតិកភ័ណ្ឌយូណេស្កូបង្កការព្រួយបារម្ភ» (អេភី ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២៤)

[23] អង្គការលើកលែងទោសអន្តរជាតិ «កម្ពុជា៖ 'ពុំមាននរណាម្នាក់ចង់ចាកចេញពីកន្លែងរស់នៅរបស់ខ្លួនឡើយ'៖ ការបណ្តេញចេញទ្រង់ទ្រាយធំដោយបង្ខំនៅតំបន់អង្គរ ជាតំបន់បេតិកភ័ណ្ឌពិភពលោករបស់អង្គការយូណេស្កូ» (ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០២៣)

ឱ្យកម្ពុជាដោះស្រាយឆ្លើយតបនឹងការចោទប្រកាន់របស់អង្គការលើកលែងទោសអន្តរជាតិឱ្យបានត្រឹមថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤។[24]

រាជរដ្ឋាភិបាលកម្ពុជា បាន**ជំទាស់ចំពោះការសន្និដ្ឋានរបស់អង្គការលើកលែងទោសអន្តរជាតិ** ដោយលើកហេតុផលថា ខ្លួនកំពុងប្តូរទីតាំង *«ក្រុមអនាធិបតេយ្យ»* ដែលពាក់ព័ន្ធនឹង *«ការកាន់កាប់ដីបេតិកភណ្ឌដោយខុសច្បាប់»*។ អង្គការលើកលែងទោសអន្តរជាតិបានឆ្លើយតបដោយគូសបញ្ជាក់ថា ក្រុមគ្រួសារប្រជាពលរដ្ឋមួយចំនួនដែលត្រូវបានផ្លាស់ប្តូរទីលំនៅបានរាយការណ៍ថា ពួកគាត់បានរស់នៅលើទឹកដីតំបន់អង្គរនេះ **ជាច្រើនជំនាន់មកហើយ**។[25] នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានសន្យាប្រែក្លាយ តំបន់រុនតាឯក និងពាក់ស្នែង ដែលជាកន្លែងតាំងទីលំនៅថ្មីមួយទៀតទៅជាក្រុងគំរូ។[26] នៅខែមីនា ឆ្នាំ២០២៤ អ្នកស្រាវជ្រាវអង្គការលើកលែងទោសអន្តរជាតិបានលើកឡើងថា ស្ថានភាពនៅតំបន់រុនតាឯកមានភាពប្រសើរឡើង ប៉ុន្តែបានកត់សម្គាល់ឃើញថា អាជ្ញាធរ**មិនបាន**ដោះស្រាយបញ្ហាបំណុល និងការបាត់បង់ចំណូលរបស់ប្រជាពលរដ្ឋនោះទេ។[27] នៅខែមេសា ឆ្នាំ២០២៤ គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅតំបន់រុនតាឯកសម្រេចបាន៧០%។[28] នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ គណៈកម្មាធិការបេតិកភណ្ឌពិភពលោក បានផ្តល់អនុសាសន៍ឱ្យ**ក្រុមអធិការកិច្ច** ចុះពិនិត្យទីតាំងជម្លោះក្នុងឧទ្យានបុរាណវិទ្យាអង្គរ ដោយលើកឡើងពីការព្រួយបារម្ភ *«អំពីរបាយការណ៍ភាគីទីបីទាក់ទងនឹង **ការផ្លាស់ទីលំនៅរបស់ប្រពលរដ្ឋដោយបង្ខំដែលអាចនឹងកើតមានឡើង**»* ។[29]

## ខ. ប្រជាពលរដ្ឋបឹងតាមោករងការបង្ខំឱ្យទទួលយកកញ្ចប់សំណងដ៏អយុត្តិធម៌

នៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា បឹងតាមោក ដែលជាបឹងដ៏ធំបំផុតរបស់រាជធានីភ្នំពេញគឺជាសម្បត្តិរបស់រដ្ឋ។[30] ក្រោយមក មាត់បឹងដែលធ្លាប់តែជាដី**លំនៅឋានរបស់ប្រជាពលរដ្ឋក្រីក្រប្រមាណ**

---

[24] យូណេស្កូ៖ «ប្រតិកម្មរបស់អង្គការយូណេស្កូចំពោះរបាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិស្តីពីតំបន់អង្គរ» (ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០២៣)

[25] ដាវីដ រ៉ាយស៊ីង «កម្ពុជាថ្លែងការពារការផ្លាស់ទីលំនៅប្រជាពលរដ្ឋចេញពីតំបន់ប្រាសាទអង្គរវត្តដ៏ល្បីល្បាញ» ( *អេភី* ថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០២៤)

[26] អេខេភី «តំបន់រុនតាឯកនឹងក្លាយជាទីក្រុងនាពេលអនាគតដ៏ខ្លី» ( *ខ្មែរថាមស៍* ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ២០២៣)

[27] ដាវីដ រ៉ាយស៊ីង "កម្ពុជាថ្លែងការពារការផ្លាស់ទីលំនៅប្រជាពលរដ្ឋចេញពីតំបន់ប្រាសាទអង្គរវត្តដ៏ល្បីល្បាញ" ( *អេភី* ថ្ងៃទី ៤ ខែមីនា ឆ្នាំ២០២៤)

[28] ថន វិបុល «រដ្ឋាភិបាលនឹងកែប្រែតំបន់រុនតាឯក និងពាក់ស្នែងជាក្រុងគំរូ» ( *ខ្មែរថាមស៍* ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤)

[29] វិទ្យុអាស៊ីសេរី ភាសាខ្មែរ `«យូណេស្កូនឹងបញ្ជូនក្រុមអធិការកិច្ចចុះពិនិត្យតំបន់ប្រាសាទអង្គរវត្តរបស់កម្ពុជា» (អ អែហ្វ អេ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤)

[30] អង្គការសមាគមធាងត្នោត «បឹងតាមោក ឬបឹងកប់ស្រូវ - ព័ត៌មាន និងតួលេខ #៤៣» (ខែមេសា ឆ្នាំ២០២១)

**៣១៩ គ្រួសារ**[31] ត្រូវបានកាត់ចេញជាប្លង់ក្បាលដី ដើម្បីចែកទៅឱ្យឥស្សរជនដែលជាប់ខ្សែស្រឡាយ និងមានខ្នងជាអ្នកមានអំណាចសម្រាប់គម្រោងអភិវឌ្ឍន៍អចលនទ្រព្យ។[32] កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ អាជ្ញាធរខណ្ឌព្រែកព្នៅ និងនគរបាលបាន**បណ្តេញប្រជាពលរដ្ឋក្នុងមូលដ្ឋានប្រមាណ ១០០ គ្រួសារដោយបង្ខំ** ដោយមិនបានជូនដំណឹង ឬពិគ្រោះយោបល់នោះទេ ហើយបានរុះរើ និង/ឬដុតបំផ្លាញផ្ទះរបស់ពួកគាត់ក្នុងគ្រានោះដែរ។[33] នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ មន្ត្រីអាជ្ញាធរបានកម្ទេចផ្ទះចំនួន ១១ខ្នង បន្ទាប់ពីម្ចាស់ផ្ទះ**ជំទាស់ការផ្តល់សំណងក្រោមតម្លៃទីផ្សារសម្រាប់ការផ្លាស់ប្តូរទីលំនៅ**។ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ម្នាក់បាននិយាយថា **កញ្ចប់សំណងនោះមិនគ្រប់គ្រាន់ឡើយ** ប៉ុន្តែបានបន្ថែមថា ប្រជាពលរដ្ឋចំនួន ១២គ្រួសារ បានទទួលយកសំណងដោយសារការភ័យខ្លាចការគំរាមកំហែងពីសំណាក់អាជ្ញាធរ។[34]

កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ អាជ្ញាធរ**បានកម្ទេចតូបលក់អាហារមួយកន្លែងរបស់**អ្នកស្រី គង់ តឿ ជាពលរដ្ឋរស់នៅភូមិសំរោងត្បូង។ ចំណាត់ការនេះបានបង្កឱ្យមានការប៉ះទង្គិចគ្នា ដែលក្នុងអំឡុងពេលនោះ ប្រជាពលរដ្ឋមួយចំនួនដែលបានប្រមូលគ្នាទៅជួយគាត់នោះ បានរងរបួសស្រាល។[35] នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ អ្នកស្រី គង់ តឿ រួមជាមួយសាច់ញាតិ ៤នាក់ និងអ្នកជិតខាង ២នាក់ **បានទទួលដីកាកោះហៅពីតុលាការ** ដោយបង្គាប់ឱ្យពួកគាត់ចូលខ្លួននៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសាកសួរពាក់ព័ន្ធនឹងករណីឧប្បត្តិហេតុនេះ។[36] នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ ប្រជាពលរដ្ឋបាននាំគ្នាតវ៉ាម្តងទៀត ដើម្បីព្យាយាមរារាំងគ្រឿងចក្រមិនឱ្យបំផ្លាញទ្រព្យសម្បត្តិរបស់ពួកគាត់ ដែលនាំឱ្យមានការប៉ះទង្គិចគ្នាជាមួយមន្ត្រីមូលដ្ឋាន។[37] គិតត្រឹមដើមឆ្នាំ២០២៤ ប្រជាពលរដ្ឋមូលដ្ឋានប្រមាណជា ២០០គ្រួសារ នៅតែស្នើសុំឱ្យអាជ្ញាធរកាត់ផ្ទៃដីចំនួន ៤ហិកតា ចេញពីគម្រោងអភិវឌ្ឍន៍ដើម្បីឱ្យពួកគាត់អាចបន្តរស់នៅក្នុងតំបន់របស់ខ្លួនបាន។[38] ប្រជាពលរដ្ឋជាង ១០នាក់ បានទទួលដីកាកោះហៅពីតុលាការ ក៏ព្រោះតែពួកគាត់ប្រឆាំងនឹងការបណ្តេញចេញ ឬការបំផ្លាញទ្រព្យសម្បត្តិពីសំណាក់អាជ្ញាធរ

---

31 អង្គការសមាគមជាងត្នោត «បឹងចុងក្រោយ - ព័ត៌មាន និងតួលេខ #៤០» (ខែធ្នូ ឆ្នាំ២០១៩)

32 កំណត់ត្រា «ឧកញ៉ាដែលមានទំនាក់ទំនងក្រុមគ្រួសារនាយករដ្ឋមន្ត្រីបានទទួលការចែកដីបឹងតាមោក» (ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣)

33 អង្គការសមាគមជាងត្នោត «សមាគមជាងត្នោត អំពាវនាវឱ្យបញ្ឈប់រាល់ការបណ្តេញចេញអំឡុងផ្ទុះជំងឺកូវីដ-១៩ ហើយចេញផ្សាយលទ្ធផលស្រាវជ្រាវថ្មីអំពី ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី» (ពុំមានបង្ហាញកាលបរិច្ឆេទ)

34 គេង យ៉ាលីរ៉ូស៊ី «អាជ្ញាធរបណ្តេញពលរដ្ឋដែលរស់នៅជាប់បឹងតាមោក» (ខេមបូឌាណេស ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២)

35 វិទ្យុអាស៊ីសេរី ភាសាខ្មែរ «អាជីវករលក់ម្ហូបអាហារសម្តែងការខឹងសម្បារក្រោយនគរបាលក្រុងភ្នំពេញ កម្ទេចតូបរបស់ពួកគាត់ក្នុងករណីជម្លោះដីធ្លី» (អ អែហ្វ អេ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣)

36 ផុន សុជីវ័ន្ត «ប្រជាពលរដ្ឋបឹងតាមោក ៧ នាក់រងការចោទប្រកាន់ពីបទបង្អាក់ការកម្ទេចតូបលក់បន្លែ» (ខេមបូចា ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤)

37 វិទ្យុអាស៊ីសេរី ភាសាខ្មែរ «ប្រជាពលរដ្ឋដែលប្រឡាក់ប្រឡូកដោយភក់ ប៉ះទង្គិចជាមួយអាជ្ញាធរ ដែលព្យាយាមកម្ទេចផ្ទះរបស់ពួកគាត់» (អ អែហ្វ អេ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤)

38 ប្រពភដូចបានដាក់បង្ហាញនៅលេខយោង៣៧ ខាងលើ

មូលដ្ឋាន។[39]

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ សមាជិកសហគមន៍ប្រមាណ ៤០នាក់ បានដើរទៅកាន់ព្រះបរមរាជវាំង ដើម្បីដាក់ញត្តិស្វែងរកព្រះរាជអន្តរាគមន៍ពីព្រះមហាក្សត្រជួយដោះស្រាយករណីនេះ។ មន្ត្រីព្រះបរមរាជវាំងបានអះអាងថា ព្រះបរមរាជវាំងមិនទទួលយកញត្តិបែបនេះទេ ហើយស្នើឱ្យប្រជាពលរដ្ឋដាក់ញត្តិទៅសាលារាជធានីភ្នំពេញ ឬការិយាល័យនាយករដ្ឋមន្ត្រី។ តំណាងសហគមន៍បាននិយាយថា ពួកគាត់បានប្រើអស់ជម្រើសហើយ ប៉ុន្តែគ្មានទទួលបានលទ្ធផលអ្វីឡើយ។[40] នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ សារព័ត៌មាន ខេមបូចា បានរាយការណ៍ថាក្រុមគ្រួសារប្រជាពលរដ្ឋដែលនៅបន្តរស់នៅលើដីជម្លោះ**បានបោះបង់ការតស៊ូទាមទារសំណងសមរម្យ**។ ប្រជាពលរដ្ឋជាច្រើនបាននិយាយថាពួកគាត់មានអារម្មណ៍ **បង្ខំចិត្តទទួលយកដំណោះស្រាយអយុត្តិធម៌** ដើម្បីជៀសវាងការធ្វើទុក្ខបុកម្នេញបន្ថែមទៀត ដោយបានលើកឡើងអំពីបទចោទប្រកាន់តាមផ្លូវច្បាប់មកលើសមាជិកសហគមន៍ និងការបំភិតបំភ័យពីសំណាក់អាជ្ញាធរមូលដ្ឋាន។[41]

## គ. ប្រជាពលរដ្ឋជាង ៣០០ គ្រួសាររងការបណ្តេញចេញដោយបង្ខំនៅខេត្តព្រះវិហារ

នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤ អាជ្ញាធរ**បានដុតបំផ្លាញផ្ទះសម្បែង និងបណ្តេញប្រជាពលរដ្ឋចេញ**ពីដីធ្លីដែលត្រូវបានផ្តល់ទៅឱ្យក្រុមហ៊ុនសិលាដាម៉ិច ក្នុងស្រុកគូលែន ខេត្តព្រះវិហារ។ អាជ្ញាធរបានប្រើឧស្ម័នបង្ហូរទឹកភ្នែក និងបាញ់គ្រាប់កៅស៊ូ ដើម្បីបំបែកក្រុមប្រជាពលរដ្ឋប្រហែល១៣០នាក់ ដែលបានព្យាយាមរារាំងអាជ្ញាធរ។[42] អ្នកភូមិប្រមាណ៤០នាក់ ត្រូវបានចាប់ខ្លួននាពេលនោះ។[43] យោងតាមព័ត៌មានដែល ម.ស.ម.ក ទទួលបាន **មានប្រជាពលរដ្ឋជាង ៣០០គ្រួសារ មកពីភូមិចំនួនបីត្រូវបានបណ្តេញចេញ** ទាំងប្រជាពលរដ្ឋដែលបានតាំងលំនៅអចិន្ត្រៃយ៍ជាយូរមកហើយ និងប្រជាពលរដ្ឋមកពីខេត្តផ្សេងៗ ដែលបានមកតាំងទីលំនៅចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៧ នៅលើដីមានជម្លោះ។ តាមសេចក្តីរាយការណ៍បានឱ្យដឹងថា អ្នកចំណូលថ្មីទាំងនេះបានទទួលការធានាផ្ទាល់មាត់ថា

---

[39] ផុន សុជីវ័ត្ថ «ប្រជាពលរដ្ឋបឹងតាមោក ៧ នាក់រងការចោទប្រកាន់ពីបទបង្អាក់ការកម្ទេចគូបលក់បន្លែ» (ខេមបូចា ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤)

[40] សុវណ្ណ ស្រីពេជ្រ «ប្រជាពលរដ្ឋបឹងតាមោក សុំព្រះរាជអន្តរាគមន៍ពីព្រះមហាក្សត្រដោះស្រាយជម្លោះដីធ្លី» (ខេមបូចា ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤)

[41] សុវណ្ណ ស្រីពេជ្រ «ល្បែងបានបញ្ចប់ករណីនៅបឹងតាមោក៖ អ្នកភូមិសំរេចត្បូងទទួលយកសំណងពីរដ្ឋាភិបាល ក្រោយមានការតវ៉ា និងការផ្តន្ទាទោស (ខេមបូចា ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤)

[42] វិទ្យុអាស៊ីសេរី ភាសាខ្មែរ «អាជ្ញាធរបាញ់ឧស្ម័នបង្ហូរទឹកភ្នែកមកលើអ្នកតវ៉ាជម្លោះដីធ្លីនៅប្រទេសកម្ពុជាភាគខាងជើង» (អ អែហ្វ អេ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤)

[43] អ៊ឹង សៀ «អាជ្ញាធរខេត្តព្រះវិហារឃាត់ខ្លួនអ្នកភូមិ និងបាញ់អាវុធ ក្នុងករណីប៉ះទង្គិចគ្នាជុំវិញជម្លោះដីធ្លី» (ខេមបូចា ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤)

មានសិទ្ធិតាំងទីលំនៅលើដីនោះពីសំណាក់បុគ្គលដែលគេមិនស្គាល់អត្តសញ្ញាណ ឬបានទិញដីពីឈ្មួញកណ្តាល ដែលទំនងជាបានបោកប្រាស់ពួកគាត់ ព្រោះអ្នកទាំងនោះមិនមានប័ណ្ណកម្មសិទ្ធិដីធ្លីជាផ្លូវការឡើយ។

នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៤ តុលាការខេត្តព្រះវិហារបាន**ចោទប្រកាន់អ្នកភូមិចំនួន ២៩នាក់ ក្នុងចំណោមអ្នកភូមិដែលត្រូវបានឃុំខ្លួន**ពីបទ *«រុករានដីព្រៃ និងហ៊ុមព័ទ្ធដីដើម្បីយកកម្មសិទ្ធិ»* ។ បន្ទាប់មក អ្នកភូមិ ៤នាក់ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ ខណៈនៅសល់ ២៥ នាក់ រួមទាំងស្ត្រី ១២ នាក់ផង ត្រូវបាន**បញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្នរង់ចាំការកាត់ទោស**។[44] នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤ **អ្នកភូមិទាំងអស់ត្រូវបានដោះលែង**ឱ្យនៅក្រៅឃុំបន្ទាប់ពីការស៊ើបអង្កេតបានរកឃើញថាពួកគាត់ចាញ់បោកឈ្មួញកណ្តាល។[45] នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ អភិបាលខេត្តព្រះវិហារ លោក គីម រិទ្ធី ថ្លែងទៅកាន់អ្នកភូមិក្នុងស្រុកគូលែន ដោយសន្យាថា ផ្ទៃដី ១.០០០ ហិកតា ដែលបានផ្តល់ទៅឱ្យក្រុមហ៊ុនសិលាដាម៉ិចនឹងត្រូវបានបែងចែកដល់ប្រជាពលរដ្ឋ១០០គ្រួសារ ក្នុងចំណោម ពលរដ្ឋ៣០០គ្រួសារ ដែលរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍។ លោក**មិនបានបញ្ជាក់ទេថាតើអ្នកដែលចូលរួមការតវ៉ាកាលពីថ្ងៃទី០៦ ខែមីនា នឹងមានសិទ្ធិទទួលបានដីនោះ ឬមួយយ៉ាងណា**។[46]

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ លោក កើត សារ៉ាយ ប្រធានសមាគមសម្ព័ន្ធនិស្សិតបញ្ញវ័ន្តខ្មែរ មានប្រសាសន៍ថា អ្នកភូមិប្រហែល ១០០នាក់ ដែលត្រូវបានបណ្តេញចេញកាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤ **កំពុងលាក់ខ្លួននៅក្នុងព្រៃដោយសារភ័យខ្លាចគេចាប់ខ្លួន**។ លោកបានបន្ថែមថា ពួកគាត់ត្រូវបង្ខំចិត្តប្រើប្រាស់អង្រឹងចាស់ៗ និងតង់ប្លាស្ទិកសម្រាប់ជ្រកកោន ហើយពឹងផ្អែកលើទឹកធ្មិន និងការនេសាទដើម្បីរស់។[47] នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤ **លោក កើត សារ៉ាយ ត្រូវបានចាប់ខ្លួន**នៅរាជធានីភ្នំពេញ និងរងការចោទប្រកាន់ពី *«បទមិនរាងចាលក្នុងបទមជ្ឈិម បន្ទាប់ពីការផ្តន្ទាទោសពីបទមជ្ឈិម»* និង *«ញុះញង់ឱ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ»* ។[48] សាលាដំបូងរាជធានីភ្នំពេញបានលើកឡើងថា ការអះអាងរបស់លោក សារ៉ាយ ជា *«ព័ត៌មានមិនពិត»* ដើម្បី *«ញុះញង់អ្នកភូមិឱ្យប្រឆាំងនឹងរដ្ឋាភិបាល»*។ លោកត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៤។[49]

---

[44] អង្គការលីកាដូ "ប្រជាពលរដ្ឋ ២៥ នាក់ត្រូវបានឃុំខ្លួននៅក្នុងករណីជម្លោះដីធ្លីខេត្តព្រះវិហារ" (ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤)

[45] រុន ស្រីដែត «ប្រជាពលរដ្ឋស្រុកគូលែនត្រូវបានដោះលែងឱ្យនៅក្រៅឃុំ ប៉ុន្តែ គ្មានកន្លែងត្រូវទៅ ក្រោយបាត់បង់ដីធ្លី មុខរបរ និងក្តីសង្ឃឹម» (ខេមបូចា ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៤)

[46] វិទ្យុអាស៊ីសេរី ភាសាខ្មែរ «ក្រោយការប៉ះទង្គិច អភិបាលខេត្តនិយាយថា ដីមានជម្លោះមួយផ្នែកនឹងចែកទៅឱ្យអ្នកភូមិ» (អ អែហ្វ អេ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤)

[47] វិទ្យុអាស៊ីសេរីភាសាខ្មែរ «ក្រោយការប៉ះទង្គិច អ្នកភូមិដែលត្រូវបានបណ្តេញចេញ កំពុងលាក់ខ្លួនក្នុងព្រៃ ដោយភ័យខ្លាចការចាប់ខ្លួន» (អ អែហ្វ អេ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤)

[48] អង្គការលីកាដូ «ប្រធានក្រុមសកម្មជននិស្សិតត្រូវបានចាប់ខ្លួន និងបញ្ជូនឱ្យឃុំខ្លួនបណ្តោះអាសន្ន» (ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៤)

[49] ឃួន ណារីម «អំពាវនាវឱ្យដោះលែងអ្នកការពារសិទ្ធិមនុស្ស លោក កើត សារ៉ាយ ដែលរងការចោទប្រកាន់ពីបទញុះញង់នៅខេត្តព្រះវិហារ» (ខាមបូចា ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤)

## ៣. ករណីគួរឱ្យបារម្ភដែលកំពុងកើតមាន

ក្នុងអំឡុងរយៈពេលរាយការណ៍ ម.ស.ម.ក បានចងក្រងឯកសារករណីគួរឱ្យបារម្ភមួយចំនួន ដែលអាចមានសក្តានុពលនាំឱ្យមានការបណ្តេញចេញដោយបង្ខំ។ បញ្ហារួមនៃករណីទាំងនេះគឺ **កង្វះការទំនាក់ទំនងប្រកបដោយតម្លាភាព និងការចូលរួមធ្វើការឱ្យបានត្រឹមត្រូវជាមួយប្រជាពលរដ្ឋ** ដែលបង្កការភាន់ច្រឡំ ការភ័យខ្លាចការបណ្តេញចេញ និងការព្រួយបារម្ភអំពីសំណងមិនសមរម្យ។

### ក. ក្តីបារម្ភអំពីសំណង និងតម្លាភាពក្នុងគម្រោងព្រែកជីកហ្វូណនតេជោ

នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំពិធីបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ដែលជាគម្រោងផ្លូវទឹកតភ្ជាប់ពីរាជធានីភ្នំពេញទៅខេត្តកែប ដោយឆ្លងកាត់ខេត្តកណ្តាល តាកែវ និងខេត្តកំពត។ នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤ ឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល មានប្រសាសន៍ថា ការសាងសង់ព្រែកជីកនេះនឹង**ប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ១.៥៨៥ គ្រួសារ ដីលំនៅដ្ឋានចំនួនប្រមាណ ១៤៩.៥ ហិកតា និងដីស្រែ និងចម្ការចំនួនប្រមាណ ២.៩០០ ហិកតា**។[50] លោក ស៊ុន ចាន់ថុល បានគូសបញ្ជាក់ផងដែរថា រាជរដ្ឋាភិបាលកម្ពុជាកំពុងរៀបចំផែនការផ្តល់សំណងសមរម្យ និងការតាំងទីលំនៅថ្មីសម្រាប់អ្នកដែលរងផលប៉ះពាល់[51] ជាការសន្យាមួយដែលលោកបានអះអាងជាថ្មីម្តងទៀតនៅក្នុងពិធីបើកការដ្ឋានសាងសង់ព្រែកជីកនោះថា *«ទាក់ទងនឹងអ្នកភូមិដែលដីផ្ទះ និងដីស្រែចម្ការរបស់គាត់ត្រូវរងផលប៉ះពាល់ដោយគម្រោងនេះ ខ្ញុំធានាថា រដ្ឋាភិបាលបានសិក្សាយ៉ាងហ្មត់ចត់ និង [បានអនុម័ត] វិធានការដោះស្រាយបញ្ហានោះ **ដើម្បីធានាបាននូវសំណងសមរម្យ**»*។[52]

នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ សារព័ត៌មាន ខេមបូចា បានរាយការណ៍ថា ប្រជាពលរដ្ឋរស់នៅតាមបន្ទាត់គម្រោងព្រែកជីកនោះ **មិនទាន់ទទួលបានដំណឹងអំពីកញ្ចប់សំណង** នៅឡើយទេ។ នៅពេលសារព័ត៌មានខេមបូចា ទាក់ទងទៅអ្នកនាំពាក្យក្រសួងសាធារណការ និងដឹកជញ្ជូន បានបញ្ជាក់ថា ក្រុមការងារអន្តរក្រសួង ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ នឹងទទួលខុសត្រូវក្នុងការគ្រប់គ្រងផលប៉ះពាល់នៃគម្រោងលើសហគមន៍មូលដ្ឋាន។ ទោះជាយ៉ាងណា មន្ត្រីនាំពាក្យរូបនោះមិនបានផ្តល់ការឆ្លើយតប

[50] សឹង និមល «ព្រែកជីកហ្វូណនតេជោ - ការក្រេឡេកមើលការគាំទ្រពីមហាជន យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងសំណង ខណៈពិធីបើកការដ្ឋានសាងសង់ខិតជិតមកដល់» (ខេមបូចា ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤)

[51] តាំង វីនិត «ប្តេជ្ញាមានភាពយុត្តិធម៌៖ រដ្ឋាភិបាលធ្វើការរៀបចំសំណងដល់អ្នកដែលរងផលប៉ះពាល់ពីគម្រោងព្រែកជីកហ្វូណនតេជោ» (ខ្មែរថាមស៍ ថ្ងៃទី០៦ ខែ ឧសភា ឆ្នាំ២០២៤)

[52] យួន ណារីម សឹង និមល និងតាំង ប៉ោហ្គិច «ព្រែកជីកហ្វូណនតេជោ បើកការដ្ឋានសាងសង់ ដោយក្តីសង្ឃឹមពីជោគជ័យផ្នែកសេដ្ឋកិច្ច ខណៈប្រជាពលរដ្ឋរងផលប៉ះពាល់ទទួលការសន្យាថា នឹងបានសំណង» (ខេមបូចា ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៤)

ឡើយ នៅពេលសួរថាហេតុអ្វីបានជាពុំមានការជូនដំណឹងដល់ប្រជាពលរដ្ឋរងផលប៉ះពាល់។[53] អត្ថបទសារព័ត៌មានមួយចំនួនក្នុងខែកក្កដា សីហា និងដើមខែកញ្ញា បានបញ្ជាក់ថា សហគមន៍មូលដ្ឋាន**នៅតែមិនទាន់ទទួលបានព័ត៌មានណាមួយឡើយ** ដោយក្នុងនោះប្រជាពលរដ្ឋមួយចំនួនបានសម្តែងការព្រួយបារម្ភថា ពួកគាត់**អាចនឹងត្រូវគេផ្តល់កញ្ចប់សំណងទាបជាងតម្លៃទីផ្សារ**។[54]

នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤ ឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល **បានជំរុញឱ្យសហគមន៍ដែលរងផលប៉ះពាល់រក្សាភាពអត់ធ្មត់** ដោយបន្ថែមថា រដ្ឋាភិបាល**មិនទាន់បានយកដីកន្លែងណាមួយជុំ**សម្រាប់ធ្វើការអភិវឌ្ឍគម្រោងនេះនៅឡើយទេ។ នៅថ្ងៃទី០៣ ខែកញ្ញា តាមសេចក្តីរាយការណ៍ រាជរដ្ឋាភិបាលកម្ពុជា បានពង្រឹងសមាសភាពនៃគណៈកម្មាធិការដោះស្រាយផលប៉ះពាល់ព្រែកជីកហ្វូណនតេជោដើម្បីពន្លឿនដំណើរការសំណង។ យោងតាមរបាយការណ៍បឋមថ្មីដែលបានចុះផ្សាយដោយកាសែត ខ្មែរថាមស៍ នៅថ្ងៃទី០៤ ខែកញ្ញា ការសាងសង់ព្រែកជីកនេះ ត្រូវបានគេរំពឹងថា នៅពេលនេះ**នឹងប៉ះពាល់លំនៅឋានជិត ១០.០០០ ខ្នង និងដីស្រែចម្ការជាង ៧.០០០ ហិកតា**។[55] **ភាពមិនស៊ីង្វាក់គ្នានៃតួលេខអំពីផលប៉ះពាល់**ត្រឹមរយៈពេលនេះ គួបផ្សំជាមួយនឹង**កង្វះការផ្សព្វផ្សាយឱ្យបានច្បាស់លាស់អំពីសំណងផង** និងកង្វះការពិគ្រោះយោបល់ជាមុនជាមួយសហគមន៍ដែលរងផលប៉ះពាល់ផងនោះ បានបង្កឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង។

## ខ. ប្រជាពលរដ្ឋជាង ១.៣១៨ គ្រួសារ ប្រឈមការគំរាមបណ្តេញចេញដោយបង្ខំនៅខេត្តក្រចេះ

កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ ប្រជាពលរដ្ឋប្រមាណ ៦០នាក់ តំណាងឱ្យ ១.៣១៨គ្រួសារ មកពីភូមិចំនួនប្រាំ ក្នុងស្រុកសំបូរ ខេត្តក្រចេះ បានប្រមូលផ្តុំគ្នានៅមុខក្រសួងមហាផ្ទៃដើម្បីស្វែងរកអន្តរាគមន៍ពីរដ្ឋាភិបាល ក្នុងការ**ទប់ស្កាត់ការបាត់បង់ដីធ្លីរបស់ពួកគាត់ទៅលើក្រុមហ៊ុនយុវជនកសិកម្មស្វាយរៀង**។ ប្រជាពលរដ្ឋ

---

53 សឹង និមល «ការសាងសង់ប្រែកជីកហ្វូណនតេជោចាប់ផ្តើមនៅខែសីហា ប្រជាពលរដ្ឋរស់នៅតាមគម្រោងព្រែកជីកពុំទទួលបានព័ត៌មានពីសំណងឡើយ» (ខេមបូចា ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤)

54 ឃួន ណារីម សឹង និមល និងតាំង ប៉ោហ្គិច «ព្រែកជីកហ្វូណនតេជោ បើកការដ្ឋានសាងសង់ ដោយក្តីសង្ឃឹមពីជោគជ័យផ្នែកសេដ្ឋកិច្ច ខណៈប្រជាពលរដ្ឋរងផលប៉ះពាល់ទទួលការសន្យាថា នឹងបានសំណង» (ខេមបូចា ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៤) សឹង និមល «ព្រែកជីកហ្វូណនតេជោ -ការក្រេឡេកមើលការគាំទ្រពីមហាជន យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងសំណង ខណៈពិធីបើកការដ្ឋានសាងសង់ខិតជិតមកដល់" (ខេមបូចា ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤) ជា សំនៀង "ប្រជាពលរដ្ឋទាមទារសំណងសមរម្យពីគម្រោងព្រែកជីកនៅកម្ពុជា» (មេកុង្គអាយ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៤) តន វិបុល «ដំណោះស្រាយកាន់តែលឿន៖ រដ្ឋាភិបាលពន្លឿនដំណើរការដោះស្រាយសំណងសម្រាប់គម្រោងព្រែកជីកហ្វូណនតេជោ» (ខ្មែរថាមស៍ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៤)

55 តន វិបុល «ដំណោះស្រាយកាន់តែលឿន៖ រដ្ឋាភិបាលពន្លឿនដំណើរការដោះស្រាយសំណងសម្រាប់គម្រោងព្រែកជីកហ្វូណនតេជោ» (ខ្មែរថាមស៍ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៤)

បានមករស់នៅ និងធ្វើស្រែចម្ការលើដីជម្លោះនេះតាំងពីទសវត្សរ៍ឆ្នាំ១៩៨០ មកម្លេះ។

បើតាមប្រជាពលរដ្ឋរងផលប៉ះពាល់បានឱ្យដឹងថា ក្រុមហ៊ុន កាម៉ាដេនូ វេនឈ័រ ដំបូងឡើយ បានវិនិយោគនៅតំបន់នោះ ហើយបានបោះបង្គោលព្រំដីបានត្រឹមត្រូវជាមួយសហគមន៍ក្នុងឆ្នាំ២០១២។ នៅឆ្នាំ២០១៣ ក្រុមហ៊ុនកាម៉ាដេនូ បានសហការជាមួយក្រុមហ៊ុនយុវជនកសិកម្មស្វាយរៀង ដាំអំពៅ ហើយពេលនោះក៏មិនមានបញ្ហាអ្វីកើតឡើងដែរ។ ប៉ុន្តែ នៅចុងខែឧសភា ឆ្នាំ២០២៤ ក្រុមហ៊ុនយុវជនកសិកម្មស្វាយរៀងបាន**ចាប់ផ្តើមប្រើប្រាស់គ្រឿងចក្រឈូសឆាយផ្ទះសម្បែង និងដំណាំរបស់ប្រជាពលរដ្ឋ** ដោយអះអាងថាដីនេះជាផ្នែកមួយនៃគម្រោងរបស់ខ្លួន ហើយបានចោទប្រកាន់អ្នកភូមិក្នុងតំបន់ថាបានទន្ទ្រានដីនោះ។ តាមសេចក្តីរាយការណ៍ ផ្ទះចំនួន ៥ខ្នង ត្រូវបានបំផ្លាញ។

ប្រជាពលរដ្ឋរងគ្រោះបាននិយាយថា អភិបាលរងស្រុកសំបូរ លោក ចេង គឹមជប់ **បានគប់គិតជាមួយក្រុមហ៊ុន ហើយគំរាមចាប់ខ្លួនអ្នកដែលជំទាស់នឹងបញ្ហានោះ**។ អ្នកភូមិបាននិយាយថា ពួកគាត់ត្រូវបានគេ**ដាក់សម្ពាធបង្ខំឱ្យចាកចេញ**ពីលំនៅឋានរបស់ខ្លួន ជាថ្នូរនឹងប្រាក់សំណងតិចតួចចន្លោះពី ១០០.០០០ ទៅ ២០០.០០០ រៀល ក្នុងមួយ គ្រួសារ។ ពួកគាត់ក៏បានអះអាងដែរថា អាជ្ញាធរមូលដ្ឋានបានបោះបង្គោលយកព្រំដីដូនតា និងដីព្រៃសហគមន៍ថាជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដែលធ្វើឱ្យស្ថានការណ៍កាន់តែធ្ងន់ធ្ងរថែមទៀត ។[56]

## គ. គម្រោងពង្រីកប្រឡាយក្នុងខេត្តកណ្តាលបង្កឱ្យប្រជាពលរដ្ឋរាប់រយគ្រួសារភ័យខ្លាចការបណ្តេញចេញ

នៅថ្ងៃទី២១ ខែសីហា ឆ្នាំ ២០២៤ គ្រឿងចក្របានចាប់ផ្តើមដំណើរការពង្រីកប្រឡាយមេ ៨៨ នៅក្នុងឃុំបឹងខ្យាង និងឃុំព្រែកស្លែង នៃខេត្តកណ្តាល ដែលប៉ះពាល់ដល់សហគមន៍រស់នៅសងខាងប្រឡាយទាំងនោះ។ ខណៈការជីកកកាយចេះតែបន្ត លំនៅឋានមួយចំនួនត្រូវបានបាញ់ថ្នាំពណ៌ និងមានបោះបង្គោលនៅជុំវិញលំនៅឋានទាំងនោះ។ ចំណាត់ការបែបនេះបានធ្វើឱ្យមានការភ្ញាក់ផ្អើលដល់ប្រជាពលរដ្ឋរាប់រយគ្រួសារក្នុងមូលដ្ឋាន ដែលភាគច្រើនពួកគាត់**មិនត្រូវបានគេជូនដំណឹងជាមុនឡើយ**។ មេភូមិម្នាក់ដែលសម្ភាសន៍ដោយសារព័ត៌មាន ខេមបូចា បាននិយាយថា គាត់ក៏មិនមានព័ត៌មានអំពីគម្រោង ឬផលប៉ះពាល់ដែលអាចកើតមានពីគម្រោងនោះដែរ។[57] គេនៅពុំទាន់ច្បាស់ទេថាតើមានប្រជាពលរដ្ឋប៉ុន្មានគ្រួសារ ដែលអាចរងផលប៉ះពាល់ពីគម្រោងនេះ បើទោះបីជាបឋមនេះ

[56] ឌី ខេមបូឌា ដេលី "តំណាងប្រជាពលរដ្ឋពីខេត្តក្រចេះស្នើរដ្ឋាភិបាលបញ្ឈប់សកម្មភាពរបស់ក្រុមហ៊ុនឯកជន ដែលបំផ្លាញលំនៅដ្ឋាន និងដំណាំរបស់ពួកគាត់" [ជាភាសាខ្មែរ] (*ខេមបូឌា ដេលី* ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤)

[57] សុវណ្ណ ស្រីពេជ្រ "អ្នកភូមិក្នុងខេត្តកណ្តាល មិនទាន់មានពន្លឺជុំវិញគម្រោងប្រឡាយ ៨៨ ហើយស្នើសុំព័ត៌មានបន្ថែមពីអាជ្ញាធរ" (ខេមបូចា ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤)

មានការប៉ាន់ស្មានថាមានចន្លោះពី ១០០ ដល់ជិត ២០០ គ្រួសារ។[58]

ក្នុងចំណោមអ្នកដែលអាចរងផលប៉ះពាល់ទាំងនោះមានអ្នកស្រុកដែលទើបមកនៅថ្មី **ដែលធ្លាប់ឆ្លងកាត់ការបណ្តេញចេញ**ដោយសារការសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មីកាលពីឆ្នាំ២០២៣។ នៅពេលនោះ មានប្រជាពលរដ្ឋខ្លះ**រងការគំរាមចាត់វិធានការផ្លូវច្បាប់**នៅពេលពួកគាត់តវ៉ាដើម្បីការពារលំនៅឋាន និងទាមទារសំណងសមរម្យ។ បន្ទាប់ពីការតវ៉ាអស់រយៈពេលជាងពីរឆ្នាំ នៅទីបំផុត អ្នកភូមិមួយចំនួនដែលបានទទួលយកសំណង ហើយបានមកតាំងទីលំនៅជិតប្រឡាយនោះ។ ក្នុងពេលនេះ ប្រជាពលរដ្ឋទាំងនោះកំពុងប្រឈមនឹងហានិភ័យនៃការបណ្តេញចេញរហូតដល់ទៅពីរដងក្នុងរយៈពេលត្រឹមតែពីរឆ្នាំ ហើយពលរដ្ឋម្នាក់ក្នុងចំណោមប្រជាពលរដ្ឋទាំងនោះបានរាយការណ៍ថា កំពុងសុំព័ត៌មានបន្ថែមពីអាជ្ញាធរមូលដ្ឋានជុំវិញគម្រោងពង្រីកប្រឡាយនោះ ប៉ុន្តែ**ពុំមានអាជ្ញាធរណាម្នាក់ផ្តល់ចម្លើយថាតើមានផ្ទះចំនួនប៉ុន្មានដែលនឹងរងផលប៉ះពាល់នោះឡើយ**។ ប្រជាពលរដ្ឋរូបនោះបាននិយាយថា៖ *«យើងសម្លឹងមើលតែមុខគ្នា ព្រោះអត់ដឹងថា គេមកកម្ទេចផ្ទះយើងពេលណានោះទេ។ ខ្ញុំស្នើសុំថា រាល់ការអភិវឌ្ឍគួរមានការសហការជាមួយប្រជាពលរដ្ឋ និងមានតម្លាភាពផង»*។

## ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ករណីនៃការបណ្តេញចេញដោយបង្ខំ និងជម្លោះដីធ្លីនាពេលថ្មីៗ និងកំពុងបន្តកើតមាន នៅទូទាំងប្រទេសកម្ពុជាបង្ហាញពីក**ង្វះតម្លាភាព ការពិគ្រោះយោបល់ និងសំណងសមរម្យនៅក្នុងគម្រោងអភិវឌ្ឍន៍ និងគោលនយោបាយគ្រប់គ្រងដីធ្លី**។ ទោះបីរាជរដ្ឋាភិបាលកម្ពុជាបានបោះជំហានទៅមុខគួរកត់សម្គាល់ក្នុងការចេញប័ណ្ណកម្មសិទ្ធដីធ្លីដើម្បីបង្ការវិវាទនាពេលអនាគតក្តី ប៉ុន្តែ**ការបណ្តេញចេញជាហូរហែ និងកង្វះការចូលរួមពីសហគមន៍ដែលរងផលប៉ះពាល់**នៅតែបន្តធ្វើឱ្យខូចដល់គោលការណ៍នៃការអភិវឌ្ឍប្រកបដោយយុត្តិធម៌ និងបរិយាបន្ន។ កង្វះការផ្សព្វផ្សាយឱ្យបានច្បាស់លាស់ និងការមិនយកចិត្តទុកដាក់ចំពោះសំឡេងរបស់ប្រជាពលរដ្ឋងាយរងគ្រោះបានធ្វើឱ្យប្រជាពលរដ្ឋរាប់ពាន់គ្រួសារ មិនបានដឹងច្បាស់លាស់ អំពីអនាគតរបស់ពួកគាត់ ដោយអាចប្រឈមមុខនឹងភាពអយុត្តិធម៌ និងការបាត់បង់មុខរបរ។

**ដូច្នេះ ម.ស.ម.ក សូមផ្តល់អនុសាសន៍ដូចខាងក្រោមដល់រាជរដ្ឋាភិបាលកម្ពុជា៖**

### អនុសាសន៍៖

១. **បញ្ឈប់ជាបន្ទាន់រាល់ការបណ្តេញចេញដែលកំពុងដំណើរការ** រហូតទាល់តែមានការចរចាពីសំណង និង

[58] យាង សុខមាន "ពលរដ្ឋជាង ១០០ គ្រួសារក្នុងឃុំបឹងខ្យាង រងផលប៉ះពាល់ពីគម្រោងពង្រីកប្រឡាយរបស់រដ្ឋ" [ជាភាសាខ្មែរ] (ខេមបូចា ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៤)

វិធានការតាំងទីលំនៅថ្មី **ដែលទទួលការយល់ព្រមពីសហគមន៍ដែលរងផលប៉ះពាល់**។

២. ធានាថា **បានពិគ្រោះយោបល់ និងជូនដំណឹងពេញលេញដល់** សហគមន៍ដែលរងផលប៉ះពាល់ទាំងអស់ មុនពេលចាប់ផ្តើមគម្រោងអភិវឌ្ឍន៍ណាមួយ។ គួររៀបចំឱ្យមានដំណើរការប្រកបដោយតម្លាភាព ដើម្បីផ្តល់ព័ត៌មានលម្អិតអំពី**ផលប៉ះពាល់ និងកញ្ចប់សំណង** ព្រមជាមួយនិងការផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ឱ្យសហគមន៍ផ្តល់មតិត្រឡប់។

៣. ធានាថា សំណងសម្រាប់អ្នកដែលរងផលប៉ះពាល់ដោយសារការបណ្តេញចេញ និងគម្រោងអភិវឌ្ឍន៍ ជា**សំណងសមរម្យ ទាន់ពេលវេលា និងឆ្លើយតបទៅនឹងតម្លៃទីផ្សារបច្ចុប្បន្ន**។ គួរបង្កើតយន្តការសម្រាប់**ការចរចា និងការប្តឹងជំទាស់** ដើម្បីដោះស្រាយវិវាទ និងបណ្តឹងសារទុក្ខនានា។

៤. អនុវត្តច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ ដែលការពារពីការបណ្តេញចេញដោយបង្ខំ និង**បង្កើតក្របខណ្ឌច្បាប់ដែលរឹងមាំជាងមុន ដើម្បីទប់ស្កាត់ការដណ្តើមយកដីធ្លីដោយខុសច្បាប់** និងការពារសិទ្ធិរបស់សហគមន៍ងាយរងគ្រោះ រាប់បញ្ចូលទាំងជនជនជាតិដើមផង។

**៥. អនុញ្ញាតឱ្យស្ថាប័នឯករាជ្យចូលរួមធ្វើការ** រាប់បញ្ចូលទាំងអង្គការសង្គមស៊ីវិល និងអ្នកសង្កេតការអន្តរជាតិផង ក្នុងការពិនិត្យតាមដានគម្រោងអភិវឌ្ឍន៍នានា និងផលប៉ះពាល់ពីគម្រោងទៅលើសហគមន៍មូលដ្ឋាន។ ធ្វើដូច្នេះនឹងធានាបាននូវគណនេយ្យភាព ហើយជួយកាត់បន្ថយសក្តានុពលនៃការរំលោភសិទ្ធិមនុស្ស។

៦. ធានាថា ការបណ្តេញចេញនាពេលអនាគត **អនុលោមតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ** ហើយការបណ្តេញចេញ នឹងមិនត្រូវបានធ្វើឡើងដោយពុំមានការជូនដំណឹងជាមុន ឬមាន**ការប្រើប្រាស់កម្លាំងហួសប្រមាណ ឬអសមាមាត្រនោះទេ**។

តាមរយៈការអនុវត្តតាមអនុសាសន៍ទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាអាចកសាងទំនុកចិត្តពីសំណាក់ប្រជាពលរដ្ឋរបស់ខ្លួន ទប់ស្កាត់ជម្លោះ និងការបណ្តេញចេញបន្ថែមទៀត និងធានាបានថា ការខិតខំប្រឹងប្រែងអភិវឌ្ឍមានភាពយុត្តិធម៌ និងចីរភាព៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង**លោក វណ្ណ សុផាត** អ្នកសម្របសម្រួលគម្រោង ម.ស.ម.ក តាមរយៈទូរស័ព្ទលេខ (+៨៥៥) (០) ១២ ៩៤១ ២០៦ ឬអ៊ីមែល vann.sophath@cchrcambodia.org។

----ចប់----